# រឿង
# កូនពពែវៃឆ្លាត



ឆ្នាំ ២០១០

អ្នកនិពន្ធ : លោកស្រី តឹក ស៊ីផុន
: លោកស្រី យឹម ចាន់ស្រី
អ្នករៀបរៀង : លោកស្រី ហួត សេយ៉ោន
វិចិត្រករ : លោក ឯម សត្យា

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ សេចក្តីសម្រេចលេខ ១៣៨ អវ.សសរ.
ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩០ ដើម្បីប្រើប្រាស់នៅតាមសាលារៀនមត្តេយ្យ

**គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ**

បោះពុម្ពលើកទី១ ចំនួន៥,000ក្បាល
រោងពុម្ពក្រសួងអប់រំ ឆ្នាំ១៩៩១

**អំណោយ អ៊ុយនីសែហ្វ**
DON DE L'UNICEF

បោះពុម្ពលើកទី២ដោយ : អង្គការគាំពារកុមារខ្មែរ (CYK)

ភ្នំពេញ ខែកក្កដា ឆ្នាំ២០១០

មូលនិធិ : ប្រាក់សន្សំរបស់អ្នកចូលរួមទាំងអស់នៅប្រែសណីយ៍ជប៉ុនសម្រាប់ជំនួយស្ម័គ្រចិត្តអន្តរជាតិ

ចំនួន : ៥,000ក្បាល

លេខ : CYK N10011

រោងពុម្ព : **J S R C** Printing House



មេពពែមួយ មុននឹងចេញទៅរកចំណីអាហារ បានផ្ដាំកូនពពែថា៖ "កូននៅក្នុងផ្ទះកុំដើរទៅណា បើមានអ្នកណាមកគោះទ្វារ កូនកុំបើកឱ្យសោះ ខ្លាចក្រែងឆ្កែចចកវាចូលមកស៊ីសាច់កូន"។



កូនពពែសួរ៖ "ចុះដល់ពេលម៉ែត្រឡប់មកវិញ ម៉ែធ្វើសញ្ញាអ្វីឱ្យកូនដឹង"?

មេពពែឆ្លើយ៖ "ម៉ែគោះទ្វារតុកៗ ពីរដងរួចនិយាយថា៖ ផ្លែចចកសាហាវណាស់ ដេញក្បាលវាទៅ បើកូនឮដូច្នេះចាំកូនបើកទ្វារណ៎ា"។

កូនពពែយល់ព្រមធ្វើតាមបង្គាប់ម្តាយ ម្តាយក៏ចេញទៅ។

ពេលដែលមេពពែនិងកូននិយាយគ្នា មានឆ្កែចចកមួយពួននៅក្បែរកន្លៀតទ្វារលបចាំស្តាប់។ វាបានឮពាក្យបណ្តាំមេពពែទាំងអស់។ វាបានគោះទ្វារ រួចនិយាយដូចពាក្យបណ្តាំរបស់មេពពែ។ កូនពពែឮដូច្នោះសប្បាយចិត្តណាស់ ហើយនឹកថាម្តាយត្រឡប់មកវិញ



កូនពពែប្រុងស្ទុះ ទៅបើកទ្វារភ្លាម តែរំពេចនោះកូនពពែនឹកឆ្ងល់ថាសំឡេងនេះមិនដូចសំឡេងម៉ែសោះ ក៏មិនព្រមបើកទ្វារ ហើយនិយាយថា៖ "បើពិតជាម៉ែមែន សុំម៉ែបង្ហាញជើងតាមប្រហោងទ្វារឱ្យកូនឃើញសិន"។



ឆ្កែចចកដាក់ជើងក្បែរកន្លៀតទ្វារ ចំប្រហោងតូចមួយឱ្យពពែមើល។



កូនពពែឃើញជើងខ្មៅព្រីកក៏ស្រែកឡើងថា៖ "ទេ! ទេ! អ្នកឯងមិនមែនជាម្ដាយខ្ញុំទេ! ម្ដាយខ្ញុំជើងសទេ"។



ឮដូច្នោះ ឆ្កែចចកក៏រត់តម្រង់ទៅរកអ្នកធ្វើនំ សុំម្សៅគេលាបជើងឱ្យស រួចរត់ត្រឡប់មកគោះទ្វារម្តងទៀត។

ពេលនោះកូនពពែនឹកស្មានថាម្ដាយត្រឡប់មកវិញមែន វាហៀបនឹងបើកទ្វារទៅហើយ ស្រាប់តែវាធុំក្លិនអ្វីមិនដូចក្លិនម្ដាយវាសោះ



វាក៏លបមើលតាមប្រហោងទ្វារឃើញច្បាស់ថា ជាឆ្កែចចកដែលមានជើងខាងក្រោយពីរខ្មៅ និងជើងខាងមុខពីរសដោយលាបម្សៅ។



កូនពពែនិយាយថា៖ "ណ្ហើយបងចចកអើយ បងឯងកុំមក បន្លំខ្ញុំអី ខ្ញុំដឹងអស់ហើយ ថយចេញឱ្យប្រញាប់ទៅ បន្តិចទៀត ម៉ែខ្ញុំមក គាត់នឹងវ៉ៃអ្នកឯងធ្លាយពោះស្លាប់ឥឡូវហើយ"។

ឆ្កែចចកអស់សង្ឃឹមក៏បោលទៅបាត់។



បន្តិចក្រោយមកមេពពែត្រឡប់មកដល់ កូនពពែបើកទ្វារឱ្យម្តាយរួចនិយាយរឿងរ៉ាវឆ្កែចចកជម្រាបម្តាយសព្វគ្រប់។ មេពពែស្រវាឱបកូន ហើយសរសើរថាៈ "កូនឯងឆ្លាតណាស់"។ កូនពពែក៏ថៅដោះម្តាយដែលមានរសជាតិឆ្ងាញ់។

## ក្រសួងអប់រំ យុវជន និងកីឡា
## នាយកដ្ឋានអប់រំកុមារតូច

This aid project is supported by all participants in Japan's
Postal Saving for International Voluntary Aid.
**និងអង្គការគាំពារកុមារខ្មែរ** ( CYK )

9789996317057